**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកំពង់ឆ្នាំង

*សំណុំរឿងរដ្ឋប្បវេណី*

*លេខ: ១៧៧*

*ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២*

.សាលក្រមលេខ: ៣៣ "ខ"

ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២

**ចៅក្រមជំនុំជម្រះ**

.លោក [redacted] ជាចៅក្រមសាលដំបូងខេត្តកំពង់ឆ្នាំង

.លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង

**ដើមចោទ៖**

.ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូពេទ្យ មានទីលំនៅបច្ចុប្បន្ននៅ[redacted] ឪពុកឈ្មោះ [redacted] ហេង (រ) ម្តាយឈ្មោះ [redacted] លាង (រ) ប្រពន្ធឈ្មោះ [redacted] សុវណ្ណនី មានកូន០១នាក់ ។

.មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ។

**ចុងចម្លើយ៖**

.ឈ្មោះ [redacted] សុវណ្ណនី ភេទស្រី អាយុ២៩ឆ្នាំ ជនជាតិខ្មែរអ៊ីស្លាម មុខរបរពេទ្យធ្មប មានទីលំនៅបច្ចុប្បន្ននៅ[redacted] ឪពុកឈ្មោះ [redacted] អាមីន (រ) ម្តាយឈ្មោះ [redacted] ហ្គោហ្សីយ៉ះ (រ) ប្តីឈ្មោះ [redacted] សំណាង មានកូន០១នាក់ ។

.មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ ។

## អង្គហេតុ និងចំណុចវិវាទ

**ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖**

១.ប្តឹងសុំលែងលះពីប្រពន្ធឈ្មោះ [redacted] សុវណ្ណនី ។

២.សុំសិទ្ធិគ្រប់គ្រង និងចិញ្ចឹមបីបាច់ថែរក្សាកូនប្រុសឈ្មោះ [redacted] យុត្តិរុង កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ។

៣.សុំបែងចែកទ្រព្យសម្បត្តិរួមមាន ៖

៤.ដីឡូតិ៍ ចំនួន ០១កន្លែង មានទំហំ ៥ម៉ែត្រ គុណនឹង ៣០ម៉ែត្រ ស្ថិតនៅភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ។

៥.ឡានម៉ាកCamry 07 le ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ 2AY-4445 ។

៦.ម៉ាស៊ីនអេកូ ចំនួន ០១គ្រឿង ។

**ខ.ដំណើររឿងក្តី និងចំណុចវិវាទ៖**

ខ.១ .**ការសង្ខេបអំពីរឿងក្តី**

នៅក្នុងរឿងក្តីនេះ ដើមចោទឈ្មោះ [redacted] សំណាង បានថ្លែងការណ៍ថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] សុវណ្ណនី ជាប្រពន្ធ ដើមចោទ និងចុងចម្លើយ បានទៅចុះ



Scanned with CamScanner

សំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ ។

ការរស់នៅជាមួយគ្នាជាប្ដីប្រពន្ធមានកូន០១នាក់ ឈ្មោះ [redacted] យុត្តិរុង ភេទប្រុស កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ លុះក្រោយមកការរស់នៅជាមួយគ្នាចេះតែមានការឈ្លោះប្រកែកគ្នាជាញឹកញាប់ ។

នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ នៅពេលដែលខ្លួនជាប់រវល់យាមនៅកន្លែងធ្វើការ និងទៅញ៉ាំការមិត្តភក្តិ នៅខេត្តបាត់ដំបង ព្រឹកឡើងខ្លួនត្រឡប់មកផ្ទះវិញ មិនឃើញប្រពន្ធនៅផ្ទះនោះទេ បានចុះចេញពីផ្ទះដោយយកសំលៀកបំពាក់ និងកូន ទៅជាមួយផង ទៅរស់នៅ ជាមួយម្ដាយបង្កើតរបស់គាត់នៅខេត្តត្បូងឃ្មុំ ។

ពេលប្រពន្ធខ្លួនចេញពីផ្ទះនេះ គាត់មិនបានប្រាប់ ឬ គេរប្រាប់ខ្លួន នោះទេ ក្រោយមកខ្លួនបានតេទៅប្រពន្ធ និងបានទៅយកប្រពន្ធនៅខេត្តត្បូងឃ្មុំ តែប្រពន្ធខ្លួនមិនព្រមមកជាមួយខ្លួនទេ ។

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ខ្លួននឹងប្រពន្ធបានសម្របសម្រួលគ្នានៅចំពោះមុខលោកមេឃុំផ្សារ ក្នុងរឿងលែងលះនេះ តែមិនត្រូវគ្នាទេ ខ្លួនក៏សម្រេចចិត្តប្ដឹងសុំលែងលះប្រពន្ធ ដោយអស់មនោសញ្ចេតនានិងគ្នាជាប្ដីប្រពន្ធតទៅទៀតហើយ ។

.ចំពោះកូនប្រុស០១នាក់ ឈ្មោះ [redacted] យុត្តិរុង កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ខ្លួនសុំសិទ្ធិគ្រប់គ្រង និងជាអ្នកមានសិទ្ធិអំណាចមេបាលើកូន តែចំពោះអាហារកិច្ចចិញ្ចឹមកូន ខ្លួនមិនទាមទារនោះទ ។

.ចំពោះទ្រព្យសម្បត្តិរួម មាន ៖

១.ដីឡូត៍ចំនួន ០១កន្លែង (មិនមានផ្ទះទេ) ដីនេះមានទំហំ៥ម៉ែត្រ គុណនឹង ៣០ម៉ែត្រ ស្ថិតនៅភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំងតម្លៃទិញ៣៣.០០០(បីម៉ឺនបីពាន់)ដុល្លារអាមេរិក លុយដែលទិញដីនេះ ខ្លួននិងប្រពន្ធ ខ្ចីពីធនាគារហត្ថាកសិករ ដើម្បី យកមកទិញ ។

២.ឡានម៉ាកCamry07Leពណ៌សពាក់ផ្លាកលេខភ្នំពេញ 2AY-4445 ទិញតម្លៃ ១៤៥០០ (មួយម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក លុយដែលទិញឡាននេះ ខ្លួននិងប្រពន្ធខ្ចីពីធនាគារហត្ថាកសិករ ដើម្បីយកមកទិញ ។

៣. ម៉ាស៊ីនអេក្វចំនួន០១គ្រឿងតម្លៃ១១៥០០(មួយម៉ឺនមួយពាន់ប្រាំរយ) ដុល្លារអាមេរិក លុយដែល ទិញម៉ាស៊ីននេះ ខ្លួននិងប្រពន្ធខ្ចីពីធនាគារហត្ថាកសិករ ដើម្បីយកមកទិញម៉ាស៊ីននេះដែរ ។

.ទ្រព្យសម្បត្តិរួមខាងលើនេះ គឺទិញនៅក្នុងចំណងអាពាហ៍ពិពាហ៍ ដែលបានខ្ចីប្រាក់ពីធនាគារហត្ថាកសិករចំនួន៨.០០០០(ប្រាំបីម៉ឺន)ដុល្លារអាមេរិកតែខ្លួនបានបង់សងធនាគារចំនួន១០ខែ សរុបទឹកប្រាក់ចំនួន១៤០០០(មួយម៉ឺនបួនពាន់)ដុល្លារអាមេរិក គិតត្រឹមថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ ។

ទ្រព្យសម្បត្តិរួមទាំងអស់ ដែលខ្លួនបានរៀបរាប់ខាងលើនេះ ប្រសិនបើចុងចម្លើយចង់បានទ្រព្យសម្បត្តិមួយណា ខ្លួនសុខចិត្តប្រគល់ឱ្យចុងចម្លើយ តែចុងចម្លើយត្រូវប្រគល់ប្រាក់តាមតម្លៃដែលបានទិញទ្រព្យសម្បត្តិទាំងអស់នោះមកឱ្យខ្លួន ។

.ចុងចម្លើយឈ្មោះ [redacted] សុវណ្ណនី បានថ្លែងការណ៍តបថា ចំពោះបញ្ហាដើមចោទ ឈ្មោះ [redacted] សំណាង បានប្ដឹងសុំលែងលះខ្លួននេះ ខ្លួនយល់ព្រមលែងលះតាមដើមចោទ ដែលបានប្ដឹងសុំលែងលះ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ។

ការអះអាងរបស់ដើមចោទដែលបានថា ខ្លួនបានចុះចោលគាត់នោះ ខ្លួនសុំបដិសេធ ដោយមូលហេតុ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ខ្លួននិងប្ដីបានឈ្លោះគ្នាខ្លាំង ហើយនៅពេលដែលឈ្លោះគ្នា

ម្តងៗ ប្តីខ្លួនតែងតែងប្រើអំពើហិង្សាមកលើខ្លួន និងបណ្តេញខ្លួនចេញពីផ្ទះ ។

លុះនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ ខ្លួនបានចេញពីផ្ទះ ដោយសារការរស់នៅមិនចុះសម្រុងគ្នា ពេលដែលខ្លួនចេញពីផ្ទះនោះ ខ្លួនក៏បានប្រាប់អាជ្ញាធរភូមិឃុំរួចដែរ ។

.ចំពោះកូនប្រុស០១ នាក់ ឈ្មោះ [redacted] យុត្តិរុង កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ខ្លួនសុំសិទ្ធិគ្រប់គ្រង និងជាអ្នកមានសិទ្ធិអំណាចមេបាលើកូន តែចំពោះអាហារកិច្ចចិញ្ចឹមកូន ខ្លួនសុំទាមទារក្នុង១ ខែចំនួន ៨០០.០០០(ប៉ែតសិបម៉ឺន)រៀល ។

មូលហេតុដែលខ្លួនសុំសិទ្ធិគ្រប់គ្រងកូន ព្រោះចំណូលខ្លួនក្នុង១ខែ ពី៦០០$ ទៅ ៧០០ $ ខ្លួនមានពេលវេលា គ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនបានច្រើន ។

.ចំពោះ ទ្រព្យសម្បត្តិរួមមាន ៖

១.ដីឡូត៍ចំនួន០១កន្លែង (មិនមានផ្ទះទេ) ដីនេះមានទំហំ៥ ម៉ែត្រ គុណនឹង ៣០ម៉ែត្រ ស្ថិតនៅភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំងទិញតម្លៃ ៣៣០០០(បីម៉ឺនបីពាន់) ដុល្លារអាមេរិក ។

២.ឡាន ម៉ាក់ Camry 07 Le ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ 2AY-4445 (តម្លៃទិញ១៩៥០០ (មួយម៉ឺនប្រាំបួនពាន់ប្រាំរយ)ដុល្លារអាមេរិក ។

៣.ម៉ាស៊ីនអេកូចំនួន០១គ្រឿងតម្លៃ១១៥០០ (មួយម៉ឺនមួយពាន់ប្រាំរយ)ដុល្លារអាមេរិក និងជំពាក់បំណុលធនាគារនោះ ខ្លួនប្រគល់ឱ្យប្តីឈ្មោះ [redacted] សំណាង ជាអ្នកមានសិទ្ធិគ្រប់គ្រង ចាត់ចែង និងសងប្រាក់ទៅធនាគារទាំងអស់ ។

.ដើមចោទឈ្មោះ [redacted] សំណាង បានថ្លែងការណ៍តបថា ខ្លួនសុំបដិសេធ ថា រឿងប្រើ អំពើហិង្សា ទៅលើចុងចម្លើយនោះមិនពិតទេ ។

.ចំពោះចុងចម្លើយដែលបានប្រគល់ទ្រព្យសម្បត្តិរួមក្នុងចំណាងអាពាហ៍ពិពាហ៍ មាន ៖

១.ដីឡូត៍ចំនួន ០១កន្លែង (មិនមានផ្ទះទេ) ដីនេះមានទំហំ៥ ម៉ែត្រ គុណនឹង៣០ម៉ែត្រ ស្ថិតនៅភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ទិញតម្លៃ៣៣.០០០(បីម៉ឺនបីពាន់) ដុល្លារអាមេរិក ។

២.ឡាន ម៉ាក់ Camry 07 Le ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ 2AY-4445 (តម្លៃទិញ ១៩៥០០ (មួយម៉ឺនប្រាំបួនពាន់ប្រាំរយ)ដុល្លារអាមេរិក ។

៣.ម៉ាស៊ីនអេកូចំនួន០១គ្រឿងតម្លៃ១១៥០០ (មួយម៉ឺនមួយពាន់ប្រាំរយ) ដុល្លារអាមេរិក និងបំណុលជំពាក់ធនាគារ ដែលចុងចម្លើយប្រគល់ឱ្យខ្លួនជាអ្នកមានសិទ្ធិគ្រប់គ្រងចាត់ចែង និងសងប្រាក់ទៅធនាគារ ខ្លួនឯកភាពទទួលយកតាមចុងចម្លើយប្រគល់ឱ្យ ។

.ចំពោះកូនប្រុស០១ នាក់ ឈ្មោះ [redacted]យុត្តិរុង កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ ២០២០ ដែលចុងចម្លើយសុំសិទ្ធិគ្រប់គ្រង និងជាអ្នកមានសិទ្ធិអំណាចមេបាលើកូននោះ ខ្លួនមិនឯកភាពនោះទេ ខ្លួនសុំសិទ្ធិគ្រប់គ្រងកូន និងជាអ្នកមានសិទ្ធិអំណាចមេបាលើកូន ពីព្រោះខ្លួនមានពេលវេលាគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន ហើយចំណូលរបស់ខ្លួនក្នុង១ខែ៣០០០$ ទៅ ៣៥០០$ ។

ចំពោះចុងចម្លើយដែលសុំទាមទារអាហារកិច្ចចិញ្ចឹមកូនក្នុង១ខែ ៨០០.០០០(ប៉ែតសិបម៉ឺន) រៀលនោះ ខ្លួនមិនមានលទ្ធភាពនោះទេ ប្រសិនបើតុលាការសម្រេចប្រគល់សិទ្ធិអំណាចមេបាលើ កូនឱ្យទៅខាងចុងចម្លើយ ខ្លួនមានលទ្ធភាពក្នុង១ខែ២០០.០០០ រៀល ។

.សាក្សីឈ្មោះ [redacted] ហៅហ្សីយ៉ះ បានថ្លែងការណ៍តបថា ខ្លួនត្រូវជាម្តាយបង្កើតរបស់ឈ្មោះ [redacted]សុវណ្ណនី ចំពោះកូនស្រីខ្លួនឈ្មោះ [redacted] សុវណ្ណនី ដែលបានសុំសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted]យុត្តិរុង នោះ គឺកូនស្រីខ្លួនមានពេលវេលាគ្រប់គ្រាន់សម្រាប់មើលថែកូន សព្វថ្ងៃនេះ ខ្លួនមិនមានធ្វើការអ្វីទេ គឺនៅតែផ្ទះ ចំពោះប្រាក់ចំណូលរបស់កូនស្រីខ្លួន ក្នុងមួយខែជាង មួយលាន រៀល សព្វថ្ងៃនេះ ខ្លួនរស់នៅភូមិទី២ ឃុំក្រូចឆ្មារ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។



Scanned with CamScanner

.សាក្សីឈ្មោះ [redacted] សាំស៊ីណា បានថ្លែងការណ៍តបថា ខ្លួនត្រូវជាប្អូនបង្កើតរបស់ឈ្មោះ [redacted] សុវណ្ណនី សព្វថ្ងៃនេះ ខ្លួនជាគ្រូបង្រៀន ហើយចំណូលក្នុង១ ខែ១.៦០០.០០០ រៀល សព្វថ្ងៃនេះ ខ្លួនរស់នៅជាមួយម្តាយ និងបងស្រីឈ្មោះ [redacted] សុវណ្ណនី កន្លែងដែលខ្លួនបង្រៀនស្ថិតនៅភូមិចារធំ ឃុំចុងជៀត ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ដែលមានចំងាយពីផ្ទះទៅសាលារៀនប្រហែល៧០ គីឡូម៉ែត្រ ។

.ដើមចោទឈ្មោះ [redacted] សំណាង បានថ្លែងការណ៍តបថា សព្វថ្ងៃនេះ ខ្លួនជាគ្រូពេទ្យ ហើយចំណូលរបស់ខ្លួនក្នុង១ខែ ពី១២លាន ទៅ១៤ លានរៀល សព្វថ្ងៃនេះ ខ្លួនរស់នៅជាមួយម្តាយបង្កើត និងមានអ្នកជួយមើលកូនម្នាក់ ។

ក្រៅពីចំណូលប្រាក់ខែ ខ្លួនបានបើកវិជ្ជាជីវៈពេទ្យ (មើលអេកូ) នៅផ្ទះរបស់ខ្លួន នៅក្នុងផ្ទះរបស់ខ្លួនមានម្តាយបង្កើត និងក្មួយស្រីម្នាក់ និងអ្នកនៅជាមួយម្នាក់ រស់នៅក្នុងផ្ទះរបស់ខ្លួនជាប្រចាំ ។

ផ្ទះដែលសាងសង់គឺជាលុយរបស់ម្តាយខ្លួន ដែលសាងសង់នៅក្នុងខែ១១ ឆ្នាំ២០១៩ មិនមែន សាងសង់ក្នុងខែ៣ ឆ្នាំ២០២១ នោះទេ សព្វថ្ងៃនេះ ម្តាយកំពុងរស់នៅជាមួយខ្លួន ។

.លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានថ្លែងការណ៍ថា ៖

I.កូនក្តីខ្លួនឈ្មោះ [redacted] សុវណ្ណនី និងឈ្មោះ [redacted] សំណាង បានរួមរស់ជាសមគ្គសង្វាសនឹងគ្នា នៅអំឡុង ខែកុម្ភៈ ឆ្នាំ២០២០ បានចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីត្រានុកូលដ្ឋានមានសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០ និងសំបុត្រអាពាហ៍ពិពាហ៍លេខ២២ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំផ្សារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ។

ការរួមរស់នៅជាមួយគ្នាក្នុងចំណងអាពាហ៍ពិពាហ៍ដោយមានកូនចំនួន០១នាក់គឺ ឈ្មោះ [redacted] យុត្តិរុង ភេទប្រុស កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ អំឡុងពេលនៃការរួមរស់ជាមួយគ្នានោះដែរ ប្តីប្រពន្ធមានទ្រព្យសម្បត្តិរួមគ្នាក្នុងនោះមាន រថយន្តម៉ាក TOYOTA CAMRY ផលិតឆ្នាំ ២០០៧ មួយគ្រឿង ដែលមានតម្លៃ១៩,៥០០(មួយម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក, ផ្ទះ នឹងដីលំនៅឋាន ទំហំ ៥ x ៣០ ម៉ែត្រ ស្ថិតនៅភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង, ដីឡូត៍ ទំហំ ៥ x ៣០ ម៉ែត្រ ដែលមានតម្លៃ៣៣០០០ (បីម៉ឺនបីពាន់) ដុល្លារអាមេរិក និង សំភារៈ ឧបករណ៍ពេទ្យមួយចំនួនទៀតក្នុងតម្លៃ១១,៥០០(មួយម៉ឺនមួយពាន់ប្រាំរយ)ដុល្លារអាមេរិក ព្រមទាំងចំណូលផ្សេងៗទៀតដែលកើតមាននៅអំឡុងពេលចំណងអាពាហ៍ពិពាហ៍ ។

ជីវិតរស់នៅរវាងប្តីប្រពន្ធមិនបានចុះសម្រុងនឹងគ្នាតែងតែងមានទំនាស់ជាញឹកញាប់ ហើយតែងជួបប្រទះបញ្ហារកាំរកូស ដោយសារតែអត្តចារិករបស់ប្តីតែងតែបង្កឡើងជាច្រើនលើកច្រើនគ្រា ហើយឈ្មោះ [redacted] សំណាង ដែលជាប្តីបានប្រើហិង្សា ទាំងផ្លូវភេទ ផ្លូវចិត្ត និងរាងកាយ បានវាយនឹងទះកំភ្លៀង បោចសក់ប្រពន្ធឈ្មោះ [redacted] សុវណ្ណនី យ៉ាងតិចក៏៣ទៅ៤ដងដែរ បណ្តាលឱ្យនាងបានរងរបួស រហូតបណ្តាលឱ្យមានជម្ងឺ Post-Partum Depression (ជម្ងឺផ្លូវចិត្ត ដោយសារតទង្វើ ទំនាស់ពាក្យសំដីគ្នាទៅវិញទៅមក ស្ទើរតែនាងជាប្រពន្ធមិនអាចស៊ូទ្រាំបាន ។

នាងបានព្យាយាមអត់ធ្មត់ ដោយគិតថាជាធម្មតាការរស់នៅជាមួយគ្នា គេចមិនផុតពីការប្រេះសាំផ្លូវចិត្ត ផ្លូវកាយ ប្រៀបបានដូចចាន់ក្នុងរាវ ហើយបានខំព្យាយាមហាត់ចិត្ត ស៊ូទ្រាំរស់នៅជាមួយគ្នាក្រែងអត្តចរិករបស់ប្តីនឹងបាន កែប្រែ ។

ផ្ទុយទៅវិញ ឈ្មោះ [redacted] សំណាង ដែលជាប្តីនៅតែបន្តប្រព្រឹត្តអំពើហិង្សាមកលើរូបនាងជា ប្រពន្ធ ប្រាក់ចំណូលដែលបានមកពីប្រាក់បៀវត្សមន្ត្រីរាជការ ព្រមទាំងចំណូលផ្សេងៗទៀត ដែលទទួលបានរួមគ្នាពីវិជ្ជាជីវៈពេទ្យ ឈ្មោះ [redacted] សំណាង បានរក្សាទុក គ្រប់គ្រង និងចាត់ចែងដោយខ្លួនឯង ។

ជាចុងក្រោយ នៅអំឡុងចុងខែមករា រហូតដល់ខែមីនា ឆ្នាំ២០២២ ឈ្មោះ [redacted] សំណាង នៅ តែរករឿងបង្កជម្លោះទាស់សំដីដាក់គ្នាទៅវិញទៅមក ដោយបានពោលពាក្យថា នឹងអស់និស្ស័យជាមួយ

គ្នាហើយ ប្រសិនបើនាងធុញថប់ក្នុងការរស់នៅជាមួយគ្នា។

ទង្វើរបស់ [redacted] សំណាង បានធ្វើ ឱ្យនាងជាប្រពន្ធមិនអាចស៊ូទ្រាំបាន ដោយអស់ទឹកចិត្ត និង មនោសញ្ចេតនា ហើយមិនអាចរួមរស់ ជាមួយគ្នាតទៅទៀតបាន ទើបនៅអំឡុងចុងខែមីនា ឆ្នាំ ២០២២ នាងក៏បាន ទូរស័ព្ទផ្តល់ព័ត៌មានទៅ អាជ្ញាធរភូមិឃុំ សម្រេចចិត្តយកទាំងកូនទៅរស់នៅជាមួយម្តាយបង្កើតនៅភូមិទី២ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ដោយមិនបានយកទ្រព្យសម្បត្តិអ្វីមកតាមខ្លួនឡើយ ហើយបានសម្រេច ដាក់ពាក្យបណ្តឹងសុំលែងលះតាមផ្លូវច្បាប់មកកាន់សាលាដំបូងខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ។

## II.ចំណាត់ការរបស់សមត្ថកិច្ចតុលាការ

### ២.១ ពាក្យបណ្តឹងបានដំណើរការៈ

ចំណាត់ការពាក្យបានដំណើរការដោយលោក [redacted] ជាចៅក្រមទទួលបន្ទុកបានចេញ ដីកាសម្រេចបង្គាប់ឱ្យប្រាក់ប្រដាប់ក្តីក្រៅពីពន្ធលេខ៣០/២២(ឆ) ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០២២ កូនក្តីខ្លួនបានអនុវត្តរួចរាល់តាមដីកាបង្គាប់របស់តុលាការ ។

តុលាការបានដាក់កាលបរិច្ឆេទ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង៧ និង ៣០នាទីព្រឹកដើម្បីធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប៉ុន្តែត្រូវបានលើកពេល ដោយចៅក្រមទទួលបន្ទុកមានធុរៈចាំបាច់។

តុលាការបានដាក់កាលបរិច្ឆេទសាជាថ្មី នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៧ និង៣០នាទីព្រឹក ដើម្បីធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប៉ុន្តែមុនពេលមួយថ្ងៃ គឺនៅថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០២២ ត្រូវបានសុំពន្យាពេលដោយមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ ឆន សំណាង ដោយមូលហេតុមិនទាន់មានសំណុំរឿងសិក្សានៅឡើយ។

តុលាការបានដាក់កាលបរិច្ឆេទសាជាថ្មី នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ៧ និង៣០នាទីព្រឹក ដើម្បីធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប៉ុន្តែត្រូវបានឈ្មោះ [redacted] សំណាង នៅពេលនោះ ត្រូវជាចុងចម្លើយ បានសុំពន្យាពេលសាជាថ្មី ដោយមូលហេតុ ម្តាយចូលសម្រាកពន្យាបាលនៅមន្ទីរពេទ្យ ហើយគ្មានអ្នកថែទាំ ទោះជាយ៉ាងនេះក្តី ក្រោយមក ស្រាប់តែលេចចេញនូវពាក្យបណ្តឹងរបស់ឈ្មោះ [redacted] សំណាង ប្តឹងសុំលែងលះប្រពន្ធឈ្មោះ [redacted] សុវណ្ណ ដែលមិនបានចុះថ្ងៃច្បាស់លាស់ក្នុងខែឧសភា ឆ្នាំ២០២២ មានការបោះត្រាចូលនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

ដោយហេតុពិនិត្យឃើញពាក្យបណ្តឹងរបស់កូនក្តីខ្លួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ និង ពាក្យបណ្តឹងរបស់ឈ្មោះ [redacted] សំណាង មិនបានចុះថ្ងៃច្បាស់លាស់ ក្នុងខែឧសភា ឆ្នាំ២០២២ ហើយ ពាក្យបណ្តឹងនោះ បានដាក់ប្តឹងក្រោយកូនក្តីខ្លួន រហូតដល់ពីរខែ ជាមួយនឹងកម្មវត្ថុ នៃបណ្តឹង អង្គហេតុតែមួយ ទីកន្លែងតែមួយ គូភាគីតែមួយ ថែមទាំងពាក្យបណ្តឹងរបស់កូនក្តីខ្លួន អាមីន សុវណ្ណនី ដែលលោក [redacted] ចៅក្រមទទួលបន្ទុកកំពុងដំណើរការនីតិវិធីផង ខ្លួនក្នុងនាម ជាមេធាវីតំណាងដោយអាណត្តិឱ្យកូនក្តី ក៏បានដាក់ពាក្យសុំបញ្ចូលសំណុំរឿងតែមួយ ពីសំណុំរឿងរដ្ឋប្បវេណីលេខ ១៧៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ទៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ១១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង។

នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ ឈ្មោះ [redacted] សំណាង ក៏បានដាក់ពាក្យស្នើសុំបញ្ចូលសំណុំ រឿងដែរ ដោយសំណើសុំបញ្ចូលសំណុំរឿងរដ្ឋប្បវេណីលេខ ១១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២២ ទៅក្នុងសំណុំរឿងរដ្ឋវេណីលេខ ១៧៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូង

ខេត្ត កំពង់ឆ្នាំង ការដាក់ពាក្យស្នើសុំនេះ ពោលគឺមុនមួយថ្ងៃនៃកាលបរិច្ឆេទដែលតុលាការបានកំណត់នីតិ វិធីត្រៀមទាញហេតុផល នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២ ។

នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២ លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំងក៏ បានចេញដីកាលេខ ៥៨/២២ សម្រេចបញ្ចូលសំណុំរឿងក្តីរដ្ឋប្បវេណីលេខ ១១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ទៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ១៧៧ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ដោយមិនបានសំអាងហេតុអាទិភាពនៃបណ្តឹង ឱ្យបានច្បាស់លាស់ឡើយ ។

ដូចបានរៀបរាប់នៅក្នុងចំណាត់ការរបស់សមត្ថកិច្ចតុលាការ នីតិវិធីរបស់តុលាការកំពុងដំណើរការ ប៉ុន្តែ ឈ្មោះ [redacted] សំណាង មានចេតនាទុច្ចរិតសុំពន្យាពេលនីតិវិធីរបស់តុលាការ ដើម្បីបានអូស បន្លាយពេលវេលាដាក់ពាក្យបណ្តឹង ស្នើសុំបញ្ចូលសំណុំរឿង ផ្ទុយនឹងគោលការណ៍បទប្បបញ្ញត្តិទូទៅ នៃក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៤ ការទទួលខុសត្រូវរបស់តុលាការ និង ភាគី បានចែងថា *"តុលាការត្រូវប្រឹងប្រែង ដើម្បីរក្សាបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណី ដោយសុចរិតនិងស្មោះត្រង់"។*

នៅក្នុងកម្មវត្ថុនៃពាក្យបណ្តឹងរបស់ដើមចោទបានស្នើសុំឲ្យតុលាការចេញសាលក្រម ដែលមាន ខ្លឹមសារៈ ១.សុំលែងលះពីប្រពន្ធឈ្មោះ [redacted] សុវណ្ណនី ២.សុំសិទ្ធិគ្រប់គ្រង ចិញ្ចឹមបីបាច់ និងថែ រក្សាកូន ឈ្មោះ [redacted] យុត្តិរុង ភេទប្រុស អាយុ ០១ឆ្នាំកន្លះ និង ៣.សុំបែងចែងចែកទ្រព្យសម្បត្តិរួម នៅក្នុងអង្គហេតុនៃបណ្តឹង ដើមចោទបានសរសេរថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ ជាមួយឈ្មោះ:[redacted]សុវណ្ណនី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០២០ ហើយក្នុងកំឡុងពេលអាពាហ៍ពិពាហ៍នេះ គឺមានកូន០១នាក់ ឈ្មោះ [redacted] យុត្តិរុង កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ និងមានទ្រព្យសម្បត្តិរួម ដី០១កន្លែង មានទីតាំងស្ថិតនៅជិតលោកតាឃ្លាំងមឿង ភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង មានលិខិតស្នើសុំបញ្ជាក់អចលនទ្រព្យចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ ទទួលស្គាល់ដោយមេឃុំផ្សារ និង រថយន្ត០១គ្រឿង ម៉ាក TOYOTA CAMRY ពណ៌ស មានលេខតួ 4T1BE46K07U534804 លេខម៉ាស៊ីន 2A78498523 ស្លាកលេខ សម្គាល់ 2AY-4445 ភ្នំពេញ លតប័ត MC10047012 ឆ្នាំផលិត2007 ចង្កូតឆ្វេង ។

ក្រោយមក នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ ខ្លួនបានទៅបំពេញការងារ នៅមន្ទីរពេទ្យបង្អែកស្រុកបរិបូណ៌ ហើយពេល ត្រលប់មកផ្ទះវិញ ប្តីក៏បានដើរមកមើលប្រពន្ធនិងកូន តែមិនឃើញ ហើយក៏បានដើររកមើលនៅ ខាងក្រៅទៀត ក៏នៅតែមិនឃើញ ក្រោយមក ទើបដឹងថា ប្រពន្ធរបស់ខ្លួន ឈ្មោះ [redacted] សុវណ្ណនី បាននាំកូនរត់ទៅស្រុកកំណើតបាត់ ក្រោយមក នៅពេលកូនឈឺធ្ងន់ ទើបគាត់យកកូនមកប្រគល់ឱ្យ ខ្លួនមើលថែរក្សានិងព្យាបាលវិញ ចំណែកឯប្រពន្ធរបស់ខ្លួន ក៏ទៅចោលទៀត។

<u>២.២ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលៈ</u>

កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង២ និង៣០នាទី រសៀល លោកចៅក្រម [redacted] អនុប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង បានដំណើរការនីតិវិធីសំណុំរឿងរដ្ឋប្បវេណីលេខ ៖ ១៧៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ បានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

ក្នុងដំណើរការនីតិវិធី ដើមចោទឈ្មោះ [redacted] សំណាង បានថ្លែងការណ៍ថា ការរស់នៅជាមួយចុងចម្លើយ ចេះតែមានការឈ្លោះប្រកែកគ្នា ហើយចុងចម្លើយបានចុះចេញពីផ្ទះដោយយកសំលៀកបំពាក់ និងកូន ទៅជាមួយផង ទៅរស់នៅជាមួយម្តាយបង្កើតនៅខេត្តត្បូងឃ្មុំ ដោយមិនបានប្រាប់ ឬ ទូរស័ព្ទ ប្រាប់នោះទេ ។ ដើមចោទបានថ្លែងការណ៍ទៀតថា នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ខ្លួននឹងប្រពន្ធបាន សម្របសម្រួលគ្នានៅចំពោះមុខ លោកមេឃុំផ្សារ ក្នុងរឿងលែងលះនេះ តែមិនត្រូវ



Scanned with CamScanner

គ្នាទេ ។ ដើមចោទក៏សម្រេចចិត្តប្ដឹងសុំលែងលះពីប្រពន្ធ ដោយអស់មនោសញ្ចេតនានិងគ្នាជាប្ដីប្រពន្ធតទៅទៀតហើយ។ ការសម្រេចលែងលះពីប្រពន្ធ ដោយបានទាមទារសិទ្ធិគ្រប់គ្រងចំពោះកូនប្រុស០១នាក់ ឈ្មោះ [redacted] យុត្តិរុង កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ ២០២០ ដោយមិនស្នើសុំសោហ៊ុយចាំបាច់ចិញ្ចឹមកូន។ ចំពោះទ្រព្យសម្បត្តិរួមក្នុងចំណងអាពាហ៍ពិពាហ៍ ភាគីទាំងពីរ បានខ្ចីប្រាក់ពីធនាគារហត្ថាកសិករ ចំនួន ៨០,០០០ ដុល្លារអាមេរិក។ ទ្រព្យសម្បត្តិរួមទាំងអស់ ប្រសិនបើចុងចម្លើយចង់បានទ្រព្យសម្បត្តិមួយ ណា ដើមចោទសុខចិត្តប្រគល់ឱ្យចុងចម្លើយ តែចុងចម្លើយត្រូវប្រគល់ប្រាក់តាមតម្លៃដែលបានទិញទ្រព្យ សម្បត្តិទាំងអស់នោះ ។

កូនក្ដីខ្លួន ដែលជាចុងចម្លើយឈ្មោះ [redacted] សុវណ្ណនី បានថ្លែងការណ៍តបថា ចំពោះបញ្ហាដើមចោទបានប្ដឹងសុំលែងលះពីខ្លួននេះ ខ្លួនយល់ព្រមលែងលះតាមដើមចោទដែលបានប្ដឹងសុំ លែងលះ។ ចំពោះការអះអាងរបស់ដើមចោទដែលថា ខ្លួនបានចុះចោលគាត់នោះ ខ្លួនសុំបដិសេធ ដោយមូលហេតុ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ខ្លួននិងប្ដីបានឈ្លោះគ្នាខ្លាំង ហើយនៅពេលដែល ឈ្លោះគ្នាម្ដងៗ គាត់តែងតែងប្រើអំពើហិង្សាមកលើខ្លួន ហើយតែងតែបណ្ដេញខ្លួនចេញពីផ្ទះ។

លុះនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០២២ ខ្លួនបានចេញពីផ្ទះ ដោយសារការរស់នៅមិនចុះសម្រុងគ្នា ពេល ដែលខ្លួនបានចេញពីផ្ទះនោះ ខ្លួនក៏បានប្រាប់អាជ្ញាធរភូមិឃុំរួចដែរ ។ ចំពោះកូនប្រុស ០១ នាក់ ឈ្មោះ [redacted] យុត្តិរុង កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ ២០២០ ខ្លួនសុំសិទ្ធិគ្រប់គ្រង និងជាអ្នកមាន សិទ្ធិអំណាចមេបាលើកូន តែចំពោះអាហារកិច្ចចិញ្ចឹមកូន ខ្លួនសុំទាមទារក្នុង១ខែ ចំនួន ៨០០.០០០ រៀល ។ មូលហេតុដែលខ្លួនសុំសិទ្ធិអំណាចមេបាគ្រប់គ្រងកូន ព្រោះចំណូលខ្លួនក្នុង១ខែ ពី៦០០$ ទៅ ៧០០ $ ហើយខ្លួនមានពេលវេលាគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនបានច្រើន ។

ចំពោះ ទ្រព្យសម្បត្តិរួមក្នុងចំណងអាពាហ៍ពិពាហ៍មានដូចដើមចោទបានថ្លែងខាងលើ ខ្លួនសូមប្រគល់ឱ្យដើមចោទ ជាអ្នកមានសិទ្ធិគ្រប់គ្រង ចាត់ចែង និងសងប្រាក់ទៅធនាគារ ។

ដើមចោទឈ្មោះ [redacted] សំណាង បានថ្លែងការណ៍តបថា ចុងចម្លើយដែលបានប្រគល់ទ្រព្យសម្បត្តិរួមក្នុងចំណងអាពាហ៍ពិពាហ៍ និងបំណុលជំពាក់ធនាគារ ដែលចុងចម្លើយប្រគល់ឱ្យខ្លួន ជាអ្នកមានសិទ្ធិគ្រប់គ្រងចាត់ចែង និងសងប្រាក់ទៅធនាគា ខ្លួនឯកភាពតាមចុងចម្លើយ ប៉ុន្តែចំពោះចុងចម្លើយដែលសុំទាមទារអាហារកិច្ចចិញ្ចឹមកូនក្នុង១ ខែ៨០០.០០០ រៀល នោះ ដើមចោទមិនមានលទ្ធភាពនោះទេ ប្រសិនបើតុលាការសម្រេចប្រគល់សិទ្ធិអំណាចមេបាលើកូនឱ្យទៅខាងចុងចម្លើយ ដើមចោទមានលទ្ធភាពក្នុង១ ខែ២០០.០០០ រៀល ។

ក្រៅពីសេចក្ដីថ្លែងការណ៍តបរបស់កូនក្ដីខ្លួន ដូចបានថ្លែងមកខាងលើនេះ គឺកូនខ្លួន សូមរក្សា និងចាត់ទុកថា ជាការជូនឯកសារឆ្លើយតបបន្ថែមដែលមានខ្លឹមសារក្នុងពាក្យបណ្ដឹងកាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២២ និងមាននៅក្នុងអង្គហេតុសង្ខេបចំណុចទី១ខាងលើ ព្រមទាំងមានភ្ជាប់មកជាមួយនូវឯកសារជាភស្តុតាងតទល់ និង ការពារខ្លួន ដូចមាននៅក្នុងចំណុចលេខ៣ខាងក្រោមនេះ។

<u>២.៣ តុលាការបានកំណត់ចំណុចវិវាទះ</u>

១.តើការប្ដឹងសុំលែងលះរបស់ដើមចោទមានមូលហេតុត្រឹមត្រូវតាមច្បាប់ដែរឬទេ?

២.តើការកំណត់អំណាចមេបាលើកូនឱ្យទៅដើមចោទ ឬ ចុងចម្លើយដែលអាចបានប្រយោជន៍ ដល់កូន?

៣.តើសោហ៊ុយចាំបាច់សម្រាប់ចញ្ចឹមបីបាច់កូនថែរក្សាកូនត្រូវកំណត់ចំនួនប៉ុន្មាន?

ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ បញ្ញត្តិនៃមាត្រា ១០៣ គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល បានចែងថា "នៅក្នុងនីតិវិធីត្រៀមសម្រាប់ការ ទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្ដីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃ

រឿងក្តីដែលគូភាគី យល់មិនស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យ រឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់ បើពិនិត្យទៅលើកំណត់ ហេតុនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ ទោះបីមានការអះអាង និងបំភ្លឺនូវវិវាទរបស់គូភាគី ប៉ុន្តែតុលាការមិនបានរៀបចំ ដើម្បីកំណត់ភស្តុតាងទាក់ទងនឹងចំណុច វិវាទឡើយ ។ ចំណុចនេះ តុលាការគប្បីកំណត់នីតិវិធីត្រៀមសាជាថ្មី ដើម្បីបានមូលដ្ឋានគ្រប់គ្រាន់ក្នុងការសម្រេចសេចក្តីក្នុងការចេញសាលក្រម ។

តាមបញ្ញត្តិមាត្រា ១១២ នៃក្រមនេះផងដែរ ការប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាអាទិ៍៖

១.ក្នុងករណីដែលភាគី ឬ អ្នកដទៃទៀតដែលពាក់ព័ន្ធប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រា នៅក្នុងកំណត់ ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ ត្រូវកត់សេចក្តីប្តឹងតវ៉ានេះ នៅក្នុងកំណត់ហេតុនោះ ។

២.ភាពត្រឹមត្រូវក្នុងការអនុវត្តតាមបញ្ញត្តិទាក់ទងនឹងរបៀបធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលអាចបញ្ជាក់បានដោយកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែប៉ុណ្ណោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកំណត់ហេតុនេះបានបាត់ ឬ បានវិនាស ។

III.<u>អំពីភស្តុតាង៖</u>

៣.១ ភស្តុងតាងជាឯកសារ

៣.១.១ រូបថតស្នាមរងរបួសការប្រព្រឹត្តអំពើហិង្សាដោយដើមចោទ មកលើកូនក្តីខ្ញុំបាទ ឈ្មោះ អាមីន សុវណ្ណនី(រូបថតចម្លង)។

៣.១.២លិខិតបញ្ជាក់ការងារចេញដោយប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្ទឹង ត្រង់ លេខ០២ សខ.សត ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២(ច្បាប់ថតចម្លង)។

៣.១.៣ វិញ្ញាបនបត្រសុខភាព ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ចេញដោយមន្ទីរសម្រាក់ព្យាបាលផ្លូវចិត្ត សាន់រ៉ាយ(ថតចម្លង)។

៣.១.៤ វិញ្ញាបនបត្ររដ្ឋបាល បញ្ជាក់ប្រាក់បៀវត្សរ៍ប្រចាំខែ លេខ៧៩៨សខ.កច ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០២២ ចេញដោយប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក នៃមន្ទីរ សុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ចាម(ថតចម្លង)។

៣.២ ភស្តុតាងជាសាក្សី

៣.២.១ ឈ្មោះ [redacted] ហ្គោហ្សីយ៉ ភេទស្រី កើតថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៦៤ អាសយដ្ឋាន [redacted] (អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរថតចម្លង)។

៣.២.២ ឈ្មោះ [redacted] សាំស៊ីណា ភេទស្រី កើតថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៩៥ អាសយដ្ឋាន [redacted] (អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរថតចម្លង)។

IV.<u>អំពីអង្គច្បាប់នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧</u>

មាត្រា ៩៧៨៖ មូលហេតុនៃការលែងលះគ្នា ត្រង់កថាខណ្ឌទី១ ចំណុច ង បានចែងថា "ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទាន ឡើងវិញបាន។ ផ្អែកតាមសេចក្តីថ្លែងការណ៍របស់ភាគីទាំងពីរខាងលើ ភាគីទាំងពីរមិនអាចធ្វើ បដិទានឡើងវិញបានទេ ព្រោះភាគីតែងតែមានទំនាស់នឹងគ្នា ថែមទាំងជារឿយៗដើមចោទតែង



Scanned with CamScanner

តែប្រើ ហិង្សាមកលើចុងចម្លើយទាំងផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត ដែលតុលាការគប្បីពិចារណាចេញសេចក្តី សម្រេចតាមបញ្ញត្តិមាត្រា ៩៧៨ នៃក្រមនេះ។

មាត្រា ៩៨០៖ ការបែងចែកទ្រព្យសម្បត្តិ កថាខណ្ឌទី១ បានចែងថា *"ក្នុងករណីដែលប្តីប្រពន្ធ លែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង។*និង កថាខណ្ឌទី២ ត្រង់ចំណុច ខ បានចែងថា ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តី ប្រពន្ធបាន ទេ ត្រូវបែងចែកទ្រព្យសម្បត្តិ *"បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗ មានសិទ្ធិទទួល យក ១ ភាគ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម"*។ ប៉ុន្តែ បើមានករណីពិសេស និង មានការទាមទាររបស់ប្តី ប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថាន ភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគ របស់ភាគីនីមួយៗចំពោះ លទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់ នៅ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូន ជាអាទិ៍។

ផ្អែកតាមបញ្ញត្តិនៃមាត្រា៩៨០ ខាងលើនេះ តុលាការគប្បីពិចារណា ដោយចេញសេចក្តីសម្រេចបែងចែកទ្រព្យរួមក្នុងចំណងអាពាហ៍ពិពាហ៍និងទ្រព្យសម្បត្តិរួមដែលកើតចេញពីទ្រព្យ ម្បត្តិដោយឡែកក្នុងចំណងអាពាហ៍ពិពាហ៍ ដោយទទួលបានចំណែកស្មើៗគ្នាតាមបញ្ញត្តិមាត្រានៃ ច្បាប់នេះ។

ព្រោះថា ក្រៅពីទ្រព្យរួមដូចដែលដើមចោទបានថ្លែងខាងលើ គឺនៅមានផ្ទះមួយល្វែងដែលបាន សាងសង់នៅអំឡុងពេលរួមសមគ្គសង្វាស ថែមទាំងអំឡុងពេលមានកូនផ្ទៃក្នុងចំណងអាពាហ៍ពិពាហ៍ ដែលបានចំណាយថវិកាសាងសង់អស់ប្រមាណ ៤០,០០០ (បួនម៉ឺន) ដុល្លារអាមេរិកដែលផ្ទះសង់ នៅលើដីដែលជាទ្រព្យដោយឡែករបស់ដើមចោទ។

ដោយឡែកទ្រព្យរួមដទៃទៀតដែលកើតចេញពីការបង្កើតមុខរបរវិជ្ជាជីវៈរួមគ្នា គ្លីនិកព្យាបាល ជម្ងឺ) ដែលក្នុងមួយខែៗ តាមការថ្លែងការណ៍របស់ដើមចោទខាងលើដែលខ្លួនរកចំណូលបានក្នុង១ ខែ ពី ៣០០០$ ទៅ ៣៥០០$ ដែលចំណូលទាំងនេះ កន្លងមកដើមចោទមិនដែលបានផ្តល់ជូនចុង ចម្លើយគ្រប់គ្រង និង ផ្តល់ជាចំណែកឡើយ។ ដូច្នេះតុលាការគប្បីពិចារណាសម្រេចបែងចែកដោយ ស្មើភាពគ្នាផងដែរ ។

មាត្រា ១០៣៧ ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា បានចែងថា៖

១.បើឪពុកម្តាយលែងលះគ្នា ត្រូវកំណត់យក ឪពុក ឬ ម្តាយណាម្ខាង ជាអ្នកមានអំណាច មេបា តាមការពិភាក្សារបស់ឪពុកម្តាយ។

២.ក្នុងករណីដែលឪពុកម្តាយបានលែងលះគ្នា នៅមុនកំណើតរបស់កូន ម្តាយគឺជាអ្នកមាន អំណាចមេបាចំពោះកូនដែលបានកើតមកនោះ ។ ប៉ុន្តែ នៅក្រោយកំណើតរបស់កូន អាចកំណត់យក ឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ បាន ។ ប៉ុន្តែ បើផ្អែកតាមកថាខណ្ឌ ទី ៣ ខាងក្រោមនេះ គឺ៖

៣.បើការពិភាក្សានៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំ អាចពិភាក្សាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប យោជន៍របស់កូននោះ ។

ផ្អែកតាមបញ្ញត្តិនៃមាត្រានេះ ត្រង់កថាខណ្ឌទី២ វាក្យខណ្ឌទី១ ត្រង់ពាក្យសរសេរ"អាច" គឺមិនមានន័យដាច់ខាតនោះទេ ដែលតុលាការគប្បីពិចារណា។

ផ្អែកតាមបញ្ញត្តិនៃមាត្រានេះផងដែរ កថាខណ្ឌទី ៣ ពាក់ព័ន្ធនឹងផលប្រយោជន៍របស់កូន។ ដូចសេចក្តីថ្លែងការណ៍របស់ភាគីទាំងពីរខាងលើ កូនប្រុសឈ្មោះ [redacted] យុត្តិរង កើតនៅថ្ងៃទី០៥

ខែវិច្ឆិកា ឆ្នាំ២០២០ ដោយគិតត្រឹមមកដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ដែលចុងចម្លើយបានដាក់ពាក្យបណ្តឹងសុំលែងលះពីប្តី ពេលនោះកូនប្រុសឈ្មោះ [redacted] យុត្តិរុង ទើបតែមានអាយុ ១ ឆ្នាំ និង ៣ ខែ ប៉ុណ្ណោះ។ ក្នុងវ័យក្មេងខ្ចីបែបនេះ ជាទូទៅក្មេងត្រូវការភាពកក់ក្តៅ និងស្ថានភាពចាំបាច់ត្រូវបិតនៅក្រោមការថែទាំដោយផ្ទាល់ពីម្តាយច្រើនជាងឪពុក។ ដូចមាននៅក្នុងសេចក្តីថ្លែងការណ៍របស់ចុងចម្លើយខាងលើ គឺចុងចម្លើយមានចំណូល និង មានពេលវេលាគ្រប់គ្រាន់ ថែមទាំងមានម្តាយ និងប្អូនស្រីបង្កើតរស់នៅជាមួយមានពេលវេលាគ្រប់គ្រាន់ចូលរួមថែទាំបីបាច់រក្សាចៅ កូនក្មួយ បាន។ ដើម្បីប្រាកដអំពីលទ្ធភាពនេះ តុលាការអាចសាកសួរសាក្សីនៅចំពោះមុខបាន។

ដោយឡែកដើមចោទវិញប្រាកដជាពុំមានពេលវេលាគ្រប់គ្រាន់មើលថែទាំបីបាច់កូន ព្រោះជាប់ភារកិច្ចការងាររដ្ឋ និង ការងារឯកជនផង ម្យ៉ាងទៀត ដើមចោទពុំមានបងប្អូនបង្កើតដែលរស់នៅជាមួយ ថែមទាំងដើមចោទសឹងតែពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការថែទាំម្តាយបង្កើតរបស់ខ្លួនដែលកំពុងបិតក្នុងវ័យជរា និង មានជម្ងឺប្រចាំកាយផង។ ការអះអាងនេះ ដោយផ្អែកប័ណ្ណអនុញ្ញាតិចូលសម្រាក់ពេទ្យ ដែលដើមចោទបានដាក់សុំពន្យាពេលចូលរួម នីតិវិធីត្រៀម កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០២២។

ហេតុដូច្នេះ តុលាការគប្បីពិចារណាតាមគតិច្បាប់ និង ស្ថានភាពជាក់ស្តែងរបស់ចុងចម្លើយ និងចេញសម្រេចបង្គាប់ឱ្យចុងចម្លើយមានសិទ្ធិអំណាចមេបា និង គ្រប់គ្រងបីបាច់ថែទាំកូនឈ្មោះ [redacted] យុត្តិរុង។

.<u>សំណូមពរ</u>

ផ្អែកតាមអង្គហេតុ ភស្តុតាងជាឯកសារ និង ជាសាក្សី ព្រមទាំងអង្គច្បាប់ ខាងលើនេះ ពិតជាមាន ទម្ងន់ករណ៍គ្រប់គ្រាន់ ជូនតុលាការពិនិត្យ និងពិចារណា ដើម្បីជាមូលដ្ឋានក្នុងការសម្រេចសេចក្តី។

ខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ សូមស្នើសុំតុលាការចេញសាលក្រមសម្រេចសេចក្តីដូចខាងក្រោម៖

១.បង្គាប់ឱ្យដើមចោទនិងចុងចម្លើយត្រូវលែងលះគ្នាចាប់ពីពេលសាលក្រមចូលជាស្ថាពរ។

២.បង្គាប់ឱ្យចុងចម្លើយជាអ្នកមាន អំណាចមេបា មានសិទ្ធិគ្រប់គ្រង ចំពោះ កូនប្រុសឈ្មោះ [redacted] យុត្តិរុង កើតនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០។

៣.បង្គាប់ឱ្យដើមចោទបង់សោហ៊ុយចាំបាច់ចិញ្ចឹមកូនក្នុងមួយខែ៨០,០០០(ប៉ែតសិបម៉ឺន) រៀល ។

៤.ទ្រព្យសម្បត្តិរួមត្រូវបែងចែកជា០២ចំណែកស្មើរគ្នាដោយក្នុងនោះរួមមាន ដី០១កន្លែង មានទីតាំងស្ថិតនៅជិតលោកតាឃ្លាំងមឿង ភូមិផ្សា ឃុំផ្សា ស្រុកបរិបូណ៌ ខេត្តកំពង់ ឆ្នាំង មានលិខិតស្នើសុំបញ្ជាក់អចលនទ្រព្យ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ ទទួល ស្គាល់ដោយមេឃុំផ្សារ ដែលមានតម្លៃ ៣៣,០០០ (បីម៉ឺនបីពាន់) ដុល្លារអាមេរិក។ រថ យន្ត០១គ្រឿង ម៉ាក TOYOTA CAMRY ពណ៌ស មានលេខតួ 4T1BE46K07U534804 លេខម៉ាស៊ីន 2A78498523 ស្លាកលេខសម្គាល់ 2AY-4445 ភ្នំពេញ លតប័ត MC1004 7012 ឆ្នាំផលិត2007 ចង្កូតឆ្វេង តម្លៃ ១៩,៥០០ (មួយម៉ឺនប្រាំបួនប្រាំរយ) ដុល្លារអាមេ រិក។ លំនៅឋានបានសាងសង់ចំណាយអស់ប្រមាណ ៤០,០០០ (បួនម៉ឺន) ដុល្លារអាម រិក បិតនៅភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង, ឧបករណ៍ពេទ្យ (ម៉ាស៊ីនអេកូ)មួយគ្រឿង តម្លៃ ១១,៥០០ (មួយម៉ឺនមួយពាន់ប្រាំរយ) ដុល្លារអាមេរិក ។

៥.បង្គាប់ឱ្យដើមចោទ ចុងចម្លើយ សហការសាមគ្គីសងបំណុលរួមរហូតចប់កាតព្វកិច្ច។

.លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានថ្លែងការណ៍ថា ៖

.ចំពោះការសុំអំណាចមេបាលើកូនប្រុសនោះ កូនក្តីខ្លួន គឺមានម្តាយរបស់គាត់ នៅជាមួយ

គាត់ ដូច្នេះ កូនក្តីខ្លួន មានពេលវេលាគ្រប់គ្រាន់ក្នុងចិញ្ចឹមបីបាច់ថែរក្សាកូនបានត្រឹមត្រូវ តែដោយឡែកខាងចុងចម្លើយឈ្មោះ [redacted] សុវណ្ណនី គាត់បានអះអាងថា ប្រាក់ខែរបស់គាត់ក្នុងមួយខែជាង ១.០០០.០០០រៀល ហើយម្តាយរបស់ចុងចម្លើយគាត់មិនមានការងារធ្វើទេ គឺនៅផ្ទះ មិនមានចំណូលនោះទេ ហើយចំពោះប្អូនស្រីរបស់ចុងចម្លើយគាត់ធ្វើគ្រូបង្រៀន ដែលមានចំងាយ ៧០គីឡូ ពីផ្ទះដែលគាត់រស់នៅ ម្យ៉ាងទៀតចំណូលរបស់ប្អូនស្រីខាងចុងចម្លើយ បានក្នុងមួយខែ១.៦០០.០០០ រៀល សរុបជារួម គឺបានប្រហែល៣.០០០.០០០រៀល បើធៀបទៅនឹងចំណូលរបស់កូនក្តីខ្លួនគឺមានភាពខុសគ្នាខ្លាំង ហើយម្យ៉ាងទៀតចុងចម្លើយ សព្វថ្ងៃធ្វើការនៅមន្ទីរពេទ្យបង្អែកស្រុក ហើយចុងចម្លើយបានជួលបន្ទប់ជួលស្នាក់នៅ បញ្ជាក់ថា គាត់មិនមានពេលវេលាគ្រប់គ្រាន់ សម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូននោះទេ ។

ខ្លួនសំណូមសុំឱ្យតុលាការមេត្តាសម្រេចទៅតាមពាក្យបណ្តឹង និងសេចក្តីថ្លែងការណ៍របស់កូនក្តីខ្លួន ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ ។

**ខ.២ .អង្គហេតុដែលគ្មានវិវាទ**

ក.ដើមចោទឈ្មោះ [redacted] សំណាង ទទួលបាននូវ៖

.ដីឡូត៍ចំនួន០១កន្លែង (មិនមានផ្ទះទេ) ដីនេះមានទំហំ៥ ម៉ែត្រ គុណនឹង ៣០ម៉ែត្រស្ថិតនៅភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង តម្លៃទិញ ៣៣.០០០(បីម៉ឺនបីពាន់) ដុល្លារអាមេរិក) ។

.ឡានម៉ាកCamry07 Le ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ 2AY-4445 (តម្លៃទិញ ១៩៥០០ (មួយម៉ឺនប្រាំបួនពាន់ប្រាំរយ)ដុល្លារអាមេរិក) ។

.ម៉ាស៊ីនអេកូចំនួន០១គ្រឿងតម្លៃ១១៥០០(មួយម៉ឺនមួយពាន់ប្រាំរយ)ដុល្លារអាមេរិក និងសងបំណុលជំពាក់ធនាគារ ដែលចុងចម្លើយប្រគល់ឱ្យដើមចោទឈ្មោះ [redacted] សំណាង ជាអ្នកមានសិទ្ធិគ្រប់គ្រង ចាត់ចែង និងសងប្រាក់ទៅធនាគារ ដើមចោទ ថាខ្លួនឯកភាពទទួលយកជាអ្នករ៉ាប់រងចេញសងធនាគារទាំងអស់ ។

**ខ.៣ .អង្គហេតុដែលមានវិវាទ**

ខ.៣.១.ដើមចោទឈ្មោះ [redacted] សំណាង សុំយកកូនប្រុស០១នាក់ ឈ្មោះ [redacted] យុត្តិរុង កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ខ្លួនសុំសិទ្ធិគ្រប់គ្រង និងជាអ្នកមានសិទ្ធិអំណាចមេបាលើកូន តែចំពោះអាហារកិច្ចចិញ្ចឹមកូន ខ្លួនមិនទាមទារនោះទ ។

ខ.៣.២.ចុងចម្លើយឈ្មោះ [redacted] សុវណ្ណនី សុំយកកូនប្រុស០១ នាក់ ឈ្មោះ [redacted] យុត្តិរុង កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ខ្លួនសុំសិទ្ធិគ្រប់គ្រង និងជាអ្នកមានសិទ្ធិអំណាចមេបាលើកូន និងទាមទារអាហារកិច្ចចិញ្ចឹមកូនក្នុង១ខែចំនួន ៨០០.០០០( ប៉ែតសិបម៉ឺន)រៀល ។

**គ.អង្គហេតុដែលគ្មានវិវាទ ៖**

១.តើការប្តឹងសុំលែងលះរបស់ដើមចោទមានមូលហេតុត្រឹមត្រូវតាមច្បាប់ដែរ ឬទេ ?

២.តើការកំណត់អំណាចមេបាលើកូន ឱ្យទៅដើមចោទ ឬ ចុងចម្លើយ ដែលអាចបានប្រយោជន៍ដល់កូន ?

៣.តើសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូន ត្រូវកំណត់ចំនួនប៉ុន្មាន ?

**ឃ.អំពីការដាក់ភស្តុតាងរបស់គូភាគី ៖**

១.មានសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ: ២២ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] សំណាង ជាប្តី និងឈ្មោះ [redacted] សុវណ្ណនី ជាប្រពន្ធ។

២.មានសៀវភៅគ្រួសារលេខ:A ០០១២២១ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] សំណាង ជាប្តី និងឈ្មោះ [redacted] សុវណ្ណនី ជាប្រពន្ធ។



Scanned with CamScanner

៣.សំបុត្របញ្ជាក់កំណើតលេខ:៩៣ចុះថ្ងៃទី១៣ខែវិច្ឆិកាឆ្នាំ២០២០កូនឈ្មោះ [redacted] យុត្តិរុង កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ ២០២០ ។

## សំអាងហេតុ

### ក.ការទទួលស្គាល់អង្គហេតុ

.ចុងចម្លើយទទួលស្គាល់ថា ចំណងអាពាហ៍ពិពាហ៍រវាង ដើមចោទ និង ចុងចម្លើយ ពិតជាត្រូវបាន បែកបាក់ ហើយគ្មានសង្ឃឹមថា នឹងអាចបដិទានឡើងវិញបានឡើយ។

ក.១.ចុងចម្លើយឈ្មោះ [redacted] សុវណ្ណនី ថ្លែងការណ៍ថា ទ្រព្យសម្បត្តិរួមមាន ៖

.ដីឡូត៍ចំនួន០១កន្លែង (មិនមានផ្ទះទេ) ដីនេះមានទំហំ៥ ម៉ែត្រ គុណនឹង ៣០ម៉ែត្រ ស្ថិតនៅភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំងទិញតម្លៃ ៣៣០០០(បីម៉ឺនបីពាន់) ដុល្លារអាមេរិក ។

.ឡានម៉ាកCamry 07 Le ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ 2AY-4445 (តម្លៃទិញ១៩៥០០ (មួយម៉ឺនប្រាំបួនពាន់ប្រាំរយ)ដុល្លារអាមេរិក ។

.ម៉ាស៊ីនអេកូចំនួន០១គ្រឿងតម្លៃ១១៥០០(មួយម៉ឺនមួយពាន់ប្រាំរយ)ដុល្លារអាមេរិក និងជំពាក់បំណុលធនាគារនោះ ខ្លួនប្រគល់ឱ្យប្ដីឈ្មោះ [redacted] សំណាង ជាអ្នកមានសិទ្ធិគ្រប់គ្រង ចាត់ចែង និងសងប្រាក់ទៅធនាគារទាំងអស់ ។

### ខ.ស្តីពីការទាមទារ សុំបែងចែកទ្រព្យសម្បត្តិ ដែលរួមមាន ៖

១.ដើមចោទឈ្មោះ [redacted] សំណាង ទទួលបាននូវ៖

.ដីឡូត៍ចំនួន០១កន្លែង (មិនមានផ្ទះទេ) ដីនេះមានទំហំ ៥ ម៉ែត្រ គុណនឹង ៣០ម៉ែត្រ ស្ថិតនៅភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង តម្លៃទិញ ៣៣.០០០(បីម៉ឺនបីពាន់) ដុល្លារអាមេរិក) ។

.ឡានម៉ាកCamry07 Le ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ 2AY-4445 (តម្លៃទិញ ១៩៥០០ (មួយម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក) ។

.ម៉ាស៊ីនអេកូចំនួន០១គ្រឿងតម្លៃ១១៥០០(មួយម៉ឺនមួយពាន់ប្រាំរយ)ដុល្លារអាមេរិក និងសងបំណុលជំពាក់ធនាគារ ដែលចុងចម្លើយប្រគល់ឱ្យដើមចោទឈ្មោះ [redacted] សំណាង ជាអ្នកមានសិទ្ធិគ្រប់គ្រង ចាត់ចែង និងសងប្រាក់ទៅធនាគារ ដើមចោទ ថាខ្លួនឯកភាពទទួលយក ជាអ្នករ៉ាប់រងចេញសងធនាគារទាំងអស់ ។

### គ.ការកំណត់អំណាចមេបាលើកូន៖

១.ដើមចោទឈ្មោះ [redacted] សំណាង សុំយកកូនប្រុស០១នាក់ ឈ្មោះ [redacted] យុត្តិរុង កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ខ្លួនសុំសិទ្ធិគ្រប់គ្រង និងជាអ្នកមានសិទ្ធិអំណាចមេបាលើកូន តែចំពោះអាហារកិច្ចចិញ្ចឹមកូន ខ្លួនមិនទាមទារនោះទ ។

២.ចុងចម្លើយឈ្មោះ [redacted] សុវណ្ណនី សុំយកកូនប្រុស០១ នាក់ ឈ្មោះ [redacted] យុត្តិរុង កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ ២០២០ ខ្លួនសុំសិទ្ធិគ្រប់គ្រង និងជាអ្នកមានសិទ្ធិអំណាចលើកូន និងទាមទារអាហារកិច្ចចិញ្ចឹមកូនក្នុង១ខែចំនួន៨០០.០០០(ប៉ែតសិបម៉ឺន)រៀល គប្បីតុលាការពិចារណា ។

### ឃ.ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី ៖

១.ការទាមទាររបស់ដើមចោទ គឺ ដើមចោទ ចាញ់ក្តី មួយផ្នែក ព្រោះការទាមទារចម្បង គឺ ទាមទារសុំលែងលះ ដូចបានរៀបរាបខាងលើ ដូច្នេះ ដើមចោទគប្បីទទួលបន្ទុកប្រាក់ប្រដាប់ក្តីមួយផ្នែកផងដែរ ។

២.តុលាការយល់ឃើញថា ដើមចោទ គប្បីទទួលបន្ទុកប្រាក់ប្រដាប់ក្តីពាក់កណ្តាល ចុងចម្លើយ ទទួលបន្ទុកប្រាក់ប្រដាប់ក្តីពាក់កណ្តាល ។

<u>**សេចក្តីសម្រេចបញ្ចប់**</u>

១. ឱ្យដើមចោទឈ្មោះ [redacted] សំណាង និង ឈ្មោះ [redacted]សុវណ្ណនី លែងលះពីគ្នា ។

ក.ឱ្យដើមចោទឈ្មោះ [redacted] សំណាង ជាឪពុក ជាអ្នកមានសិទ្ធិអំណាចមេបាលើកូន០១ នាក់ ឈ្មោះ [redacted] យុត្តិរុង កើតថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ។

ខ.ភាគីដែលគ្មានសិទ្ធិអំណាចមេបាលើកូន មានសិទ្ធិចូលជួបនិងប្រាស្រ័យទាក់ទង ជាមួយកូនបានគ្រប់ពេលវេលា ហើយភាគីដែលមានសិទ្ធិអំណាចមេបាលើកូន ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត ។

២. បែងចែកទ្រព្យសម្បត្តិដូចខាងក្រោម ៖

ក.ដីឡូត៍ចំនួន០១កន្លែង (មិនមានផ្ទះទេ) ដីនេះមានទំហំ ៥ ម៉ែត្រ គុណនឹង ៣០ម៉ែត្រ ស្ថិតនៅភូមិផ្សារ ឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ទិញតម្លៃ ៣៣.000(បីម៉ឺនបីពាន់) ដុល្លារអាមេរិក ) ។

ខ.ឡានម៉ាកCamry07Leពណ៌សពាក់ផ្លាកលេខភ្នំពេញ 2AY-4445 (តម្លៃទិញ ១៩៥០០ (មួយម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក) ។

គ.ម៉ាស៊ីនអេកូចំនួន០១គ្រឿង តម្លៃ១១៥០០ (មួយម៉ឺនមួយពាន់ប្រាំរយ) ដុល្លារអាមេរិក និងបំណុលជំពាក់ធនាគារ ដើមចោទ ជាអ្នករ៉ាប់រងចេញសង ។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ៥0% និងចុងចម្លើយ៥0% ។

.សាលក្រមនេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ។

.ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ ក្នុងរយៈពេលតាមកំណត់ច្បាប់ គិតចាប់ពីថ្ងៃទទួលសាលក្រមតទៅ ។

ថ្ងៃពុធ ៩រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កំពង់ឆ្នាំងថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២

**ចៅក្រម**

ហត្ថលេខា និងត្រា[redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៩រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កំពង់ឆ្នាំងថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner